**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ**

*អត្ថបទស្រាវជ្រាវ ស្ដីពី*

# របររកកង្កែប និង បញ្ហានៅក្នុងសហគមន៍

## ករណីសិក្សា ៖ ភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ



ដោយ *ម៉ិល វាសនា, ផុន កសិកា, ប្រែង ពិសិដ្ឋ*
វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា

*ខែកុម្ភៈ ឆ្នាំ២០១៩*

# របររកកង្កែប និង បញ្ហានៅក្នុងសហគមន៍

## ករណីសិក្សា ៖ ភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ

## *សេចក្តីផ្តើម*

*បច្ចុប្បន្ន របររកកង្កែបជារបរបន្ទាប់បន្សំមួយ និងកំពុងមានដំណើរការនៅភូមិព្រៃដក់ពរ និងភូមិផ្សេងៗទៀត ក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំងកក់ ខេត្តតាកែវ។ គេអាចរកចំណូលបានច្រើនគួរសមនិងជារៀងរាល់ថ្ងៃ ជាពិសេសនៅរដូវវស្សា តាមរយៈរបររកកង្កែបនេះ ដោយកង្កែបមានតម្រូវការនៅតាមទីផ្សារនិងមានតម្លៃខ្ពស់។ ប្រជាជនអាស្រ័យរបរនេះបានពង្រឹងជីវភាពប្រចាំថ្ងៃរបស់ខ្លួនគួរឱ្យកត់សម្គាល់ បន្ថែមលើរបរស្រែចម្ការនិងការងារជាកម្មកររោងចក្រដែលជាមុខរបរមូលដ្ឋានរបស់ប្រជាជន។*

*ទន្ទឹមនឹងកត្តាវិជ្ជមាននេះ របររកកង្កែបក៏បានបង្កជាបញ្ហាមួយចំនួននៅក្នុងសហគមន៍ផងដែរ។ របររកកង្កែបបានបង្កឱ្យមានការខូចខាតដំណាំស្រូវរបស់ប្រជាពលរដ្ឋដទៃទៀត ដែលពុំបានអាស្រ័យឬទទួលផលប្រយោជន៍ពីរបរនេះ។ កន្លងមក មានបណ្តឹងមួយចំនួនអំពីករណីនេះទៅមេភូមិ ទៅមេឃុំ ហើយរហូតមកដល់ពេលនេះក៏នៅមិនទាន់មានដំណោះស្រាយជាក់លាក់ដែលអាចទទួលយកបានទាំងសងខាងនៅឡើយដែរ។*

*អត្ថបទនេះនឹងបង្ហាញអំពីវិធីនិងបច្ចេកទេសរកកង្កែប ដែលនាំឱ្យវាក្លាយជារបរបន្ទាប់បន្សំនិងកំពុងពេញនិយមនៅភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ព្រមទាំងបង្ហាញអំពីផលអវិជ្ជមានដែលបង្កឱ្យមានបញ្ហានៅក្នុងសហគមន៍។*

## *ស្ថានភាពភូមិសាស្ត្រនៃភូមិព្រៃដក់ពរ*

*ភូមិព្រៃដក់ពរស្ថិតក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំងកក់ ខេត្តតាកែវ តាមបណ្តោយផ្លូវលំចេញពីវត្តមង្គលមានលក្ខណ៍ឆ្ពោះទៅវត្តពោធិ៍រុន។ ភូមិនេះមានព្រំប្រទល់ខាងលិចជាប់ភូមិពាក់បង្អោង ខាងជើងជាប់ភូមិព្រៃក្តួច ខាងកើតជាប់ភូមិតាសួន និងខាងត្បូងជាប់នឹងភូមិត្រពាំងស្វាយ។ ភូមិព្រៃដក់ពរមានប្រជាជនចំនួន ៨៣គ្រួសារ ត្រូវជា៤២៩នាក់ ក្នុងនោះមានស្រី២៣៣*

នាក់ ប្រុស១៩៦នាក់ លើផ្ទៃដីសរុប៥២ហិកតា។ ប្រជាជនដែលមានចំនួនច្រើនជាងគេ គឺស្ថិតនៅក្នុងអាយុក្រោម៥៥ឆ្នាំ ដោយក្នុងនោះមានច្រើនរហូតដល់៨០%[1]។

តាំងពីដើមរហូតដល់ពេលបច្ចុប្បន្ន ប្រជាជននៅក្នុងភូមិនេះពឹងអាស្រ័យជាចម្បងលើការធ្វើស្រែ និងដំណាំរួមផ្សំតិចតួចដែលប្រជាជនដាំក្នុងដីស្រែ បន្ទាប់ពីប្រមូលផលស្រូវរួច។ បច្ចុប្បន្នការងារជាកម្មករនៅតាមរោងចក្រក៏ជាប្រភពចំណូលមួយដ៏សំខាន់ដែរ។ ក្រៅពីរបរធ្វើស្រែនិងដាំដំណាំរួមផ្សំ យើងសង្កេតឃើញក្មេងៗនិងយុវជនមួយចំនួនប្រកបរបររកកង្កែបដោយប្រើលបដាក់កង្កែបនិងប្រើបង្គៃស្នឹង ដើម្បីរកចំណូលបន្ថែមសម្រាប់ជួយទ្រទ្រង់ជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ការប្រកបរបរដាក់លបកង្កែបនៅក្នុងភូមិព្រៃដក់ពរគឺ ចាប់មានឡើងប្រហែលពី១០ឆ្នាំមុននេះប៉ុណ្ណោះ[2] ។

## លបដាក់កង្កែប និង បង្កៃដាក់កង្កែប

### លបដាក់កង្កែប (លបសន្ទុះ)

តាមវចនានុក្រមខ្មែរ (វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត) *លប* ជាឈ្មោះនៃសាទុបករណ៍ ពួកទ្រូ តែមានរាងស្មើចុងស្មើដើម ឬខ្ពស់ម្ខាង ឬក៏ខ្ពស់ទាំងពីរខាង សម្រាប់ដាក់ផ្ដេកក៏មាន ដាក់បញ្ឈរក៏មាន ឱ្យមច្ឆជាតិចូលតាមប្រឹស។ បច្ចុប្បន្ននេះ នៅភូមិព្រៃដក់ពរ អ្នកប្រកបរបររកកង្កែបនិយមប្រើលបសន្ទុះ មិនប្រើលបប្រឹសទេ ព្រោះលបសន្ទុះមានប្រសិទ្ធភាពខ្ពស់ជាងក្នុងការដាក់យកកង្កែប។

លបសន្ទុះជាលបមួយប្រភេទ ធ្វើពីបន្ទោះឬស្សី មានបណ្ដោយប្រមាណ២ចំអាម និងកម្ពស់មុខកាត់ប្រមាណ១ចំអាម មានប្រលោះមួយស្ថិតនៅខាងលើដែលមានទំហំប្រមាណកន្ទះចំអាមបួនជ្រុង បិទដោយសន្ទុះលោហៈស្ដើងដែលអាចឱនទាបចូលទៅក្នុងលបដោយទម្ងន់សង្កត់ និងអាចងើបមកបិទប្រលោះមាត់លបវិញដោយចំណងកៅស៊ូយឺត។ គេអាចធ្វើប្រលោះមាត់លបនោះអំពីបន្ទោះឬស្សីមានចំនួនសេស ដូចជា ប្រលោះចំនួន៥បន្ទោះឬស្សី ប្រលោះចំនួន៧បន្ទោះឬស្សី ឬ ប្រលោះចំនួន៩បន្ទោះឬស្សី។ ជាទូទៅ គេនិយមធ្វើប្រលោះមាត់លបចំនួន៧

---

[1] ណុប សារិន អាយុ៣៩ឆ្នាំ ជាមេភូមិព្រៃដក់ពរ (សម្ភាសន៍ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦)។

[2] ណុប សារិន អាយុ៣៩ឆ្នាំ មេភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ (សម្ភាសន៍ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦)។

*ប្រលោះឫស្សី*[3] ។ ដូច្នេះ គេហៅ *លបសន្ទុះ* ទៅតាមសន្ទុះលោហៈមួយបិទជិតមាត់លប ដែលជាផ្លូវកង្កែបត្រូវចូលជាប់លបតាមសន្ទុះលោហៈនោះ។



លបសន្ទុះសម្រាប់ដាក់កង្កែប

ដោយសម្ភារៈសម្រាប់ធ្វើលបសន្ទុះសុទ្ធសឹងជាសម្ភារៈអាចរកបានដោយងាយនៅក្នុងភូមិ អ្នកប្រកបរបររកកង្កែបតែងធ្វើលបសន្ទុះនេះដោយខ្លួនឯង។ ក្នុងមួយថ្ងៃ គេអាចធ្វើលបសន្ទុះដាក់កង្កែបបានពី ៣ ទៅ ៥ លប។ «ខ្ញុំធ្វើលបដាក់កង្កែបនេះដោយខ្លួនឯង ដោយខ្ញុំរៀនចេះពីឪពុកក្មេកដែលគាត់រៀនពីអ្នកភូមិនៅត្រពាំងអណ្ដើក។ ការធ្វើលបដាក់កង្កែបនេះគឺត្រូវមានក្បួនខ្នាតត្រឹមត្រូវ ប្រសិនបើយើងធ្វើខុសក្បួនខ្នាត នោះក៏មិនមានកង្កែបចូលក្នុងលបដែរ»[4] ។ អ្នកប្រកបរបររកកង្កែបម្នាក់អាចមានលបសន្ទុះដាក់កង្កែបប្រមាណ ២០លប ឬ ៣០លប ឬអាចលើសចំនួននេះក៏មាន។

### បង្កៃ

តាមវចនានុក្រមខ្មែរ (វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត) *បង្កៃ* ជាឈ្មោះសន្ទូចមួយប្រភេទ មានដងសម្រាប់ដោត។ ក្នុងលក្ខណៈដូចគ្នានេះដែរ អ្នកភូមិព្រៃដក់ពរ ជាពិសេសអ្នកប្រកបរបររកកង្កែប ក៏ប្រើបង្កៃសម្រាប់បង្កៃយកកង្កែបដែរ ដែលគេហៅថា *បង្កៃស្ទឹង*។

---

[3] ចាន់ សុខឿន អាយុ៣៨ឆ្នាំ រស់នៅភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ (សម្ភាសន៍ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦)។

[4] ចាន់ សុខឿន អាយុ៣៨ឆ្នាំ រស់នៅភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ (សម្ភាសន៍ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦)។

*បង្គៃស្ទីង ធ្វើពីបន្ទោះឫស្សីមួយបន្ទោះ មានប្រវែងប្រមាណ២៥សង់ទីម៉ែត្រ មានខ្សែបង្គៃ (ធ្វើពីខ្សែនីឡុង) ប្រវែងប្រមាណ២៥សង់ទីម៉ែត្រ ដោយចុងម្ខាងខ្សែចងភ្ជាប់នឹងចុងដងបង្គៃ ហើយចុងខ្សែម្ខាងទៀតចងផ្លែសន្ទូច។ ជាទូទៅ គេសម្រួចគល់ដងបង្គៃឱ្យស្រួចដើម្បីឱ្យងាយដោតចូលជាប់ទៅក្នុងដី។*



*បង្គៃស្ទីង ដែលអ្នកភូមិព្រៃដក់ពរប្រើសម្រាប់បង្គៃយកកង្កែប*

## *បច្ចេកទេសដាក់លបកង្កែប (លបសន្ទះ)*

*គេអាចដាក់លបកង្កែបបានទាំងនៅរដូវប្រាំង ទាំងនៅរដូវវស្សា។ នៅរដូវប្រាំង គេដាក់លបចាប់កង្កែបនៅតាមត្រពាំងឬស្រះដែលមានទឹក ឯនៅរដូវវស្សា គេច្រើនដាក់លបចាប់កង្កែបនៅក្នុងស្រែ។ គេដាក់លបចាប់កង្កែប (លបសន្ទះ) នៅតាមស្រែទៅតាមទំហំស្រែ ពោលគឺ បើស្រែមានទំហំតូច គេដាក់លបតែមួយ តែបើស្រែមានទំហំធំ គេអាចដាក់លបពីរ ឬលើសនេះក៏មាន។ ក្នុងលបមួយ អាចមានកង្កែបចូលរហូតដល់ទៅ១០កង្កែបឬច្រើនជាងនេះ។ «ខ្ញុំដាក់លបកង្កែបនៅពេលស្រូវទុំ តាមស្រែដែលនៅមានទឹក។ ក្នុងមួយយប់ ខ្ញុំអាចដាក់បានពី ៣០ ទៅ ៤០កង្កែបសម្រាប់លបចំនួន១១»[5]។ ជាទូទៅ នៅរដូវវស្សា កង្កែបមានទំហំតូចបើធៀបទៅនឹងកង្កែបក្នុងរដូវប្រាំង តែនៅរដូវស្រូវទុំ កង្កែបមានទំហំធំ ហើយសម្បូរច្រើន។*

*ជាវិធីសាស្ត្រ អ្នកប្រកបរបររកកង្កែបពូកែ (អ្នកដាក់លបបានកង្កែបច្រើន) ត្រូវដើរពិនិត្យស្ថានភាពតាមវាលស្រែនៅពេលរសៀល ដើម្បីកំណត់ទីតាំងសម្រាប់ដាក់លបចាប់យកកង្កែបនៅ*

*[5] ចាន់ សុខឿន អាយុ៣៨ឆ្នាំ រស់នៅភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ (សម្ភាសន៍ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦)។*

ពេលព្រលប់។ គេត្រូវដើរពិនិត្យមើលតាមស្រែ ប្រសិនបើស្រែណាមានឃើញកង្កែបលោតច្រើន ឬ មានស្នាមដានដើងកង្កែប នោះគឺគេកំណត់ស្រែនោះជាទីតាំងសម្រាប់ដាក់លបចាប់យកកង្កែប។ អ្នកប្រកបរបររកកង្កែបតែងដឹងអំពីឥរិយាបថរបស់កង្កែបថា កង្កែបតែងចេញរកចំណីពីពេលព្រលប់រហូតដល់ពាក់កណ្តាលអាធ្រាត្រ។ គេច្រើនដាក់លបចាប់កង្កែបនៅតាមស្រែដែលមានទឹកតិចៗ ទាំងស្រែមានស្រូវ ទាំងស្រែមិនមានស្រូវ។

ជាទូទៅ គេដាក់លបចាប់កង្កែបនៅពេលព្រលប់ ហើយសម្ភារៈសម្រាប់ប្រកបរបរនេះមាន លបសន្ទះ (លបកង្កែប) នុយ (ដាក់ក្នុងកន្ត្រូ) ទឹកនុយ (ដាក់ក្នុងកន្ត្រូ) ចបកាប់ និងដងរែក (សម្រាប់រែកលប កន្ត្រូនុយ និងកន្ត្រូទឹកនុយ)។ នុយដាក់កង្កែបមានដូចជា ក្បាលត្រី កំពិស និងសំណល់ត្រីផ្សេងៗ ឯទឹកនុយជាទឹកដែលបានមកពីការត្រាំក្បាលត្រីនិងនុយផ្សេងៗនោះ។ អ្នកប្រកបរបររកកង្កែបម្នាក់អាចមានលបកង្កែប (លបសន្ទះ) ពីជាង ១០លបឡើងទៅ ដែលត្រូវមានដងរែកសម្រាប់រែកសម្ភារៈទាំងនេះ។

ទៅដល់ទីតាំងកំណត់ដែលត្រូវដាក់លប គេដាក់លបនៅទីតាំងដ៏សមគួរមួយ ហើយគេកាប់ដីមួយចបបិទដាក់ពីក្រោយសន្ទះលប មួយចបដាក់បិទពីឆ្វេងសន្ទះលប មួយចបដាក់បិទពីស្តាំសន្ទះលប និងមួយចបទៀតសម្រាប់ដាក់រាបខាងមុខសន្ទះលបដើម្បីធ្វើផ្លូវឱ្យកង្កែបចូលទៅស៊ីនុយ។ បន្ទាប់ពីកាប់ដីបិទមាត់លបរួចហើយ គេយកនុយក្បាលត្រីឬកំពិសដោតជាប់នឹងបន្ទះដីបិទក្រោយសន្ទះលប រួចយកទឹកនុយប្រោះក្បែរៗទីតាំងដាក់លបនោះ ដើម្បីឱ្យមានក្លិនឆ្អាបទាក់ទាញដល់សត្វកង្កែប។ ជាទូទៅ គេដាក់លបចាប់យកកង្កែបនៅក្នុងស្រែដែលមានស្រូវ ហើយគេអាចដាក់លបមួយ ឬ ពីរ ឬ ច្រើនជាងនេះ ទៅតាមទំហំស្រែ។



ការដាក់លបកង្កែប (លបសន្ទះ) ក្នុងស្រែ (មើលពីមុខ)


ការដាក់លបកង្កែប (លបសន្ទះ) ក្នុងស្រែ (មើលពីចំហៀង)

ដោយអ្នកប្រកបរបររកកង្កែបម្នាក់តែងដាក់លបច្រើនក្នុងមួយយប់ៗ ហើយក៏មានអ្នកប្រកបរបររកកង្កែបច្រើននាក់ទៀតនោះ អ្នកដាក់លបត្រូវប្រុងប្រយ័ត្នក្នុងការកំណត់ចំណាំទីតាំងដាក់លបរបស់ខ្លួន ដើម្បីកុំឱ្យវង្វេងនៅពេលមកលើកលបវិញ។ គេត្រូវចំណាំស្រែនិងចំនួនលបដែលគេបានដាក់ ហើយត្រូវធ្វើសញ្ញាសម្គាល់ ដូចជាកាប់ដីមួយចបនៅលើភ្លឺស្រែជាដើមសម្រាប់ចំណាំដើម្បីគេអាចចូលទៅរកលបក្នុងស្រែទាំងនោះឃើញ។

អ្នកមានបទពិសោធន៍ក្នុងរបរដាក់លបកង្កែបបានអះអាងថា ពេលកង្កែបចូលក្នុងលបណាមួយ វាអាចស្រែកយំរកគ្នាវាផ្សេងទៀតផងដែរ។ ក្នុងករណីលបណាមានកង្កែបធំចូលគឺលបនោះមានកង្កែបចូលតែមួយឬពីរកង្កែបប៉ុណ្ណោះ ព្រោះបើមានកង្កែបធំចូល នោះកង្កែបតូចមិនហ៊ានចូលទៀតទេ ដោយកង្កែបតូចខ្លាចកង្កែបធំខាំ។ ប៉ុន្តែ បើលបនោះមានកង្កែបតូចចូល នោះក្នុងលបនោះតែងមានកង្កែបចូលច្រើនរហូតដល់៨ឬ១០កង្កែបក៏មាន។ ជាងនេះទៀត អ្នកដាក់កង្កែបខ្លះយល់ឃើញដោយផ្ទាល់ខ្លួនថា កង្កែបដែលយំស្រែករកគ្នានោះ គឺទំនងជាក្នុងបំណងរំដោះខ្លួនវាចេញពីលបវិញផងដែរ ដោយលបមានសន្ទះ នោះពេលមានកង្កែបផ្សេងលោតចូលក្នុងលប វានឹងជាន់សន្ទះលប ហើយព្រមជាមួយគ្នានោះ កង្កែបដែលជាប់ក្នុងលបអាចឡៀតរើឬលោតចេញពីលបនោះបានវិញក៏មាន។

ក្នុងករណីបិទដីជុំវិញសន្ទះលបមិនត្រូវតាមបច្ចេកទេស នោះនឹងមានករណីកង្កែបរាផងដែរ។ កង្កែបរាមានន័យថា មានកង្កែបចូលមកស៊ីនុយអស់ តែមិនបានចូលជាប់ក្នុងលបនោះទេ។ គេអាចដឹងថាកង្កែបរាដោយសារតែគេមើលឃើញស្លាកស្នាមជើងកង្កែបមកស៊ីនុយ តែមិនឃើញមានកង្កែបក្នុងលប។ ការបិទដីជុំវិញសន្ទះលបមិនត្រូវបច្ចេកទេស ជាការបិទដីនៅសល់បន្ទោះ

ឫស្សីលប ដែលអាចឱ្យកង្កែបឈរជ្រែងជើងលើបន្ទោះឫស្សីលបនៅសងខាងមាត់លបដើម្បីស៊ីនុយ ហើយចេញទៅវិញបាន។ ហេតុនេះ គេត្រូវបិទដីឱ្យជិតជាប់នឹងសន្ទះមាត់លបដើម្បីបោកបញ្ឆោតកង្កែក ធ្វើយ៉ាងណាកុំឱ្យកង្កែបអាចស៊ីនុយបាន។ បើគេបិទដីបានជិតជាប់នឹងសន្ទះមាត់លបត្រឹមត្រូវតាមបច្ចេកទេស នោះពេលមានកង្កែបមកស៊ីនុយ គឺកង្កែបនោះត្រូវតែចូលជាប់ក្នុងលប មិនអាចមានករណីកង្កែបរានោះទេ។



ការបិទដីជុំវិញសន្ទះមាត់លបនៅសល់បន្ទោះឫស្សីលបដែលអាចនាំឱ្យមានករណីកង្កែបរា

នៅពេលលើកលប គេត្រូវលាងសម្អាតលបដែលមានប្រឡាក់ដីបិទលបមួយដំណាក់កាលសិន មុននឹងលើកយកទៅផ្ទះ។ បន្ទាប់ពីលើកលបមកដល់ផ្ទះនិងចាប់យកកង្កែបចេញអស់ហើយ តែត្រូវលាងសម្អាតលបម្តងទៀតឱ្យស្អាត រួចព្យួរទុក ដើម្បីការពារមិនឱ្យលបឆាប់ពុកផុយលឿន។ ទោះយ៉ាងណា លបធ្វើពីបន្ទោះឫស្សីអាចប្រើការបានតែត្រឹមរយៈពេលពីរឆ្នាំប៉ុណ្ណោះ។



ការលាងសម្អាតលបនៅពេលលើកលប

## ការដាក់បង្កៃកង្កែប (បង្កៃស្ទឹង)

ទោះបីជាអ្នកប្រកបរបររកកង្កែបនៅភូមិព្រៃដក់ពរនិយមប្រើលបសន្ទុះ(លបកង្កែប) ដើម្បីដាក់ចាប់យកកង្កែប ហើយចាប់បានច្រើនក្ដី តែពួកគេក៏នៅប្រើបង្កៃដែរ នោះគឺបង្កៃស្ទឹង។ បង្កៃស្ទឹង ជាប្រភេទបង្កៃដែលគេប្រើដើម្បីបង្កៃយកកង្កែបនៅពេលមានទឹកច្រើន ដូចជា ទឹកជិតលិចភ្លឺស្រែ ហើយដែលគេមិនអាចដាក់លបបាន។ គេដាក់បង្កៃយកកង្កែបនៅតាមភ្លឺស្រែ ដោយគេកាប់ដីមកដាក់លើភ្លឺស្រែ ហើយគេដោតបង្កៃស្ទឹងនេះទៅក្នុងដីនោះស្ទើរលិចចុងបង្កៃ ទុកឱ្យនៅតែខ្សែបង្កៃដែលមានផ្លែបិទជាប់នុយនៅក្នុងទឹកស្រែ។

ដោយឡែកនៅរដូវប្រាំងដែលនៅតាមស្រែមិនមានទឹក គេអាចរកកង្កែបនៅតាមស្រះ ឬត្រពាំង ដោយគេអាចប្រើលបសន្ទុះឬប្រើបង្កៃ។ ដូចគ្នាដែរ មុនពេលកំណត់ទីតាំងស្រះឬត្រពាំងណាដែលត្រូវដាក់លបឬបង្កៃ អ្នកប្រកបរបររកកង្កែបតែងដើរពិនិត្យមើលស្ថានភាពតាមស្រះឬត្រពាំងនៅពេលរសៀល ពោលគឺបើស្រះឬត្រពាំងណាមានកង្កែបលោតច្រើន ឬមានមាត់កង្កែបច្រើន នោះគេនឹងកំណត់ទីតាំងដាក់លបឬបង្កៃនៅតាមមាត់ស្រះឬត្រពាំងនោះនៅពេលព្រលប់។ ប្រសិនបើនៅស្រះឬត្រពាំងណាមិនមានកង្កែបលោតឬមិនមានមាត់កង្កែបទេ នោះគេមិនអាចដាក់លបឬបង្កៃចាប់យកកង្កែបបានទេ។

## បញ្ហានៅក្នុងសហគមន៍បង្កឡើងដោយរបររកកង្កែប

ដូចបានលើកឡើងខាងលើ អ្នកប្រកបរបររកកង្កែបនៅភូមិព្រៃដក់ពរមានច្រើននាក់ ហើយម្នាក់ៗអាចមាន ២០លប ឬ ៣០លប ឬអាចមានច្រើនជាងនេះ។ ជាមួយនេះ អ្នកប្រកបរបររកកង្កែបនិយមដាក់លបចាប់យកបង្កែបនៅកណ្ដាលស្រែដែលមានស្រូវ ជាពិសេសស្រែដែលមានទឹកតិចៗ។ ក្នុងស្រែមួយ គេអាចដាក់លបមួយឬពីរ ហើយក៏អាចមានអ្នកប្រកបរបររកកង្កែបផ្សេងទៀតដាក់នៅក្នុងស្រែតែមួយ ឬជាបន្តបន្ទាប់គ្នាស្ទើររាល់ថ្ងៃដែរ។

ជាធម្មតា ក្នុងការដាក់លបកង្កែបនៅកណ្ដាលស្រែ អ្នកដាក់លបម្នាក់ត្រូវដើរចូលទៅក្នុងស្រែបួនដើងយ៉ាងតិច(ទៅដាក់លបពីរដើង និងទៅលើកលបវិញពីរដើងទៀត)។ ប្រសិនបើមានអ្នកប្រកបរបររកកង្កែបផ្សេងទៀតដាក់លបក្នុងស្រែតែមួយដូចគ្នា នោះការដើរចូលទៅក្នុងស្រែតែមួយនឹងកាន់តែមានចំនួនច្រើនដើងជាងនេះ។ ប្រាកដណាស់ ការដើរឆ្លងកាត់ស្រូវទៅកណ្ដាលស្រែនឹងធ្វើឱ្យមានការខូចខាតស្រូវមិនខាន។ ជាងនេះទៀត ជាបច្ចេកទេសនៃការដាក់លបសន្ទុះ(លបកង្កែប) គេត្រូវកាប់ដីយ៉ាងហោចបួនចបដើម្បីបិទជុំវិញសន្ទុះមាត់លបមួយ។ ដូច្នេះប្រសិនបើស្រែមួយមានដាក់លបពីរឬច្រើនជាងនេះ ហើយដាក់ស្ទើររៀងរាល់ថ្ងៃ នោះកម្រិតនៃការខូច

*ខាតស្រូវក៏មានច្រើនដែរ ខណៈពេលដែលម្ចាស់ស្រែពុំបានទទួលផលប្រយោជន៍អ្វីពីការដាក់លបក្នុងស្រែរបស់គាត់នោះឡើយ។*

*«កន្ទុងមកមានម្ចាស់ស្រែខ្លះខឹង និងប្តឹងមកភូមិ ហើយរហូតដល់ឃុំក៏មាន»[6]។ «ជារឿយៗនៅពេលមានការប្រជុំអំពីជីវភាពភូមិឃុំ អ្នកភូមិតែងលើកយកប្រធានបទស្តីពីការដាក់លបក្នុងស្រែដើម្បីឱ្យអាជ្ញាធរជួយរកវិធីដោះស្រាយ ហើយអាជ្ញាធរក៏បានអប់រំណែនាំដល់អ្នករកស៊ីប្រកបរបរដាក់លបនេះដែរដោយធ្វើយ៉ាងណាឱ្យចេះប្រយ័ត្នប្រយែងកុំឱ្យប៉ះពាល់ដល់ស្រែស្រូវអ្នកភូមិ។ ប៉ុន្តែ ជាក់ស្តែង នៅតែមានការបង្កការខូចខាតដល់ស្រែស្រូវរបស់អ្នកភូមិជានិច្ច»[7]។ «កន្ទុងមកប្រសិនបើប្រជាជនឃើញមានលបដាក់នៅក្នុងស្រែរបស់គាត់ នោះគាត់អាចបំផ្លាញលបនោះចោល»[8]។ ការដាក់លបនៅពេលព្រលប់រវាងពីម៉ោង៦ ទៅ ៦.៣០នាទី ហើយលើកលបវិញនៅម៉ោងប្រមាណ ៤ទៀបភ្លឺ ក៏ជាវិធីមួយដើម្បីជៀសវាងការប្រឈមនឹងម្ចាស់ស្រែផងដែរ។*

*ទោះជាយ៉ាងណា ក៏មានអ្នកភូមិខ្លះអនុគ្រោះដែរ ដោយគ្រាន់តែណែនាំឱ្យអ្នកប្រកបរបររកកង្កែប ដែលសុទ្ធសឹងជាអ្នកស្គាល់គ្នា រស់នៅក្នុងភូមិជាមួយគ្នា មានការប្រុងប្រយ័ត្នកុំធ្វើឱ្យខូចខាតស្រូវរបស់គាត់ប៉ុណ្ណោះ។ ប្រសិនបើអ្នកដាក់លបមានការប្រយ័ត្នប្រយែងនិងយកចិត្តទុកដាក់ដោយដើរទៅក្នុងស្រែមិនជាន់ស្រូវ មិនកាប់ដីមានស្រូវ ហើយលុបដីវិញក្រោយពេលលើកលបនោះក៏អាចកាត់បន្ថយកម្រិតនៃការខូចខាតស្រូវបានច្រើនដែរ។*

## *សេចក្តីសន្និដ្ឋាន*

*តាមការសិក្សានៅភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំងកក់ ខេត្តតាកែវ របររកកង្កែបបានជួយសម្រួលយ៉ាងច្រើនដល់ជីវភាពគ្រួសារប្រជាជនមួយចំនួននៅក្នុងភូមិ និងជួយរួមចំណែកក្នុងការទប់ស្កាត់ការធ្វើចំណាកស្រុក ដោយរបរនេះជារបរបន្ថែមដ៏សំខាន់មួយនៅរដូវវស្សា ព្រោះវាអាចរកចំណូលប្រចាំថ្ងៃបានច្រើនជាងអ្នកចាកចេញពីផ្ទះទៅធ្វើការងារជាកម្មករសំណង់ទៅទៀត។ ប៉ុន្តែ របររកកង្កែបនេះក៏បានបង្កឱ្យមានការខូចខាតស្រូវមួយចំនួនរបស់ម្ចាស់ស្រែជាច្រើនគ្រួសារ ដែលពុំបានទទួលផលប្រយោជន៍អ្វីពីរបរនេះឡើយ។ វាទាមទារឱ្យមានការ*

[6] *ព្រំ សំអុល អាយុ៥៦ឆ្នាំ មេភូមិរងព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ (សម្ភាសន៍ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦)។*

[7] *ណុប សារិន អាយុ៣៩ឆ្នាំ មេភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ (សម្ភាសន៍ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦)។*

[8] *ជិន សារឿន អាយុ៧៨ឆ្នាំ រស់នៅភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ (សម្ភាសន៍ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦)។*

អប់រំណែនាំដល់ប្រជាជនប្រកបរបរនេះ ដោយព្យាយាមធ្វើយ៉ាងណាមិនបង្កការខូចខាតច្រើនដល់ស្រូវស្រែរបស់អ្នកដទៃ។ ការសម្របសម្រួលបានរវាងផលប្រយោជន៍ និងការខាតបង់នេះនឹងជួយពង្រឹងសាមគ្គីភាពរវាងប្រជាជនក្នុងភូមិ និងជួយរួមចំណែកក្នុងការទប់ស្កាត់ការធ្វើចំណាកស្រុករបស់ប្រជាជនក្នុងភូមិផងដែរ។

**ឯកសារពិគ្រោះ**

- វចនានុក្រមខ្មែរ ចេញផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៧ ។
- ចាន់ សុខឿន អាយុ៣៨ឆ្នាំ នៅភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើងស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសន៍ថ្ងៃ២៣ខែកញ្ញា ឆ្នាំ២០១៦)។
- ជិន សារឿន អាយុ៧៨ឆ្នាំ ជាប្រជាជនរស់នៅភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសន៍ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦)។
- ព្រំ សំអុល អាយុ៥៦ឆ្នាំ ជាមេភូមិរងព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសន៍ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៦)។
- ណុប សារិន អាយុ៣៩ ជាមេភូមិព្រៃដក់ពរ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសន៍ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦)។



*បណ្ឌិត ផុន កសិកា និង លោកស្រី មុិល វាសនា ក្នុងកិច្ចសម្ភាសន៍លោក ចាន់ សុខឿន*
*អ្នកប្រកបរបររកកង្កែបនៅក្នុងភូមិព្រៃដក់ពរ*